# តើមានអ្វីកើតឡើងប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការសវនាការ?

**រ៉ែនឌុល ឌីហ្វាល់កូ**

*(ប្រែសម្រួលជាភាសាខ្មែរដោយ គីម ម៉ារីយ៉ាន)*

## ១. ការគំរាមកំហែងចំពោះសំណុំរឿង០០២ ដោយជនជាប់ចោទប្រហែលជាមិនមានសម្បទាក្នុងការចូលរួមដំណើរការសវនាការ

*ចាប់តាំងពីការចរចារនៅដំណាក់កាលដំបូងបង្អស់ ឆ្ពោះទៅរកការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមានការព្រួយបារម្ភចំពោះសុខភាពរបស់ជនជាប់ចោទនៃសំណុំរឿង០០២ ។ ជនជាប់ចោទទាំងបួននាក់ដែលមាន នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ មានអាយុច្រើន ហើយវាអាចទៅរួចដែលជនជាប់ចោទមួយចំនួនឬទាំងអស់មិនអាចរស់រានមានជីវិតបានយូររហូតដល់បញ្ចប់ការកាត់ទោស ។ ជនជាប់ពីររូប នួន ជា និង អៀង ធីរិទ្ធ បានទាមទារថា ពួកគេគួរតែទទួលបានការអនុគ្រោះពីសវនាការដោយសារតែបញ្ហាសុខភាព ហើយជនជាប់ចោទ អៀង សារី បានស្នើសុំការសម្រួលពិសេសដោយយោងតាមស្ថានភាពជំងឺរបស់គាត់ ។ លើសពីនេះទៅទៀត នៅក្នុងពាក្យបណ្តឹងមួយទៅកាន់តុលាការក្រុមមេធាវីការពារក្តីរបស់ ជនជាប់ចោទ អៀង ធីរិទ្ធ បានលើកអំណះអំណាងថា សមាជិកនៃក្រុមការពារក្តីរបស់ខ្លួន«មិនអាចទទួលបានការណែនាំ»ពីជនជាប់ចោទ អៀង ធីរិទ្ធ ទេ ហើយបានការពារក្តីដោយមិនមានការចូលរួមយោបល់ និងជំនួយពីជនជាប់ចោទទេ ។ មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ លោក ផាត់ ពៅស៊ាង បានអះអាងបន្ថែមទៀតថា ជាងមួយឆ្នាំកន្លងមកនេះ កូនក្តីរបស់គាត់មានបញ្ហាផ្នែកស្មារតី «កាន់តែធ្ងន់ធ្ងរ» ហើយអ្នកនាំពាក្យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឡាស អូលសិន បានធ្វើការអះអាងបន្ថែមទៀតថា «ការវាយតម្លៃបន្ថែមរបស់អ្នកជំនាញទៅលើសម្បទាផ្លូវចិត្តរបស់ជនជាប់ចោទ អៀង ធីរិទ្ធ» គឺជារឿងចាំបាច់ ។ ដូច្នេះ វាបានបង្ហាញនូវលទ្ធភាពពេញលេញថា អង្គជំនុំជម្រះអាចនឹងរកឃើញថា ជនជាប់ចោទម្នាក់ ឬច្រើននាក់នៅក្នុងសំណុំរឿង០០២ មិនមានសម្បទាគ្រប់គ្រាន់នៅមុនពេលចាប់ដំណើរការសវនាការ ។ ប៉ុន្តែ ប្រសិនបើជនជាប់ចោទម្នាក់ ឬច្រើននាក់នៅក្នុងសំណុំរឿង០០២*

ត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមដំណើរការសវនាការ គេនៅមិនទាន់ច្បាស់នៅឡើយអំពីលទ្ធផលនៃសេចក្តីសម្រេចនេះ បើពិនិត្យមើលអំពីស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទ និង តាមន័យច្បាប់ ។

## ២. ការវាយតម្លៃសម្បទាជនជាប់ចោទនៅក្នុងកំរិតអន្តរជាតិ

តុលាការដែលជំនុំជម្រះឧក្រិដ្ឋកម្មអន្តរជាតិ បានដោះស្រាយបញ្ហាសម្បទារបស់ជនជាប់ចោទចាប់តាំងពីពេលមានច្បាប់ព្រហ្មទណ្ឌអន្តរជាតិទំនើបមកម្ល៉េះ ដោយសារតែសង្គ្រាមលោកលើកទីពីរ ។ នៅសាលាជំនុំជម្រះក្តីយោធាអន្តរជាតិ (International Military Tribunal) នៅនូរឹមបឹក ប្រទេសអាល្លឺម៉ង់ ការព្រួយបារម្ភទាក់ទងទៅនឹងសម្បទារបស់ជនជាប់ចោទបីនាក់ត្រូវបានលើកឡើង ។ តុលាការបានបង្គាប់ឲ្យធ្វើការវាយតម្លៃទៅលើសម្បទារបស់ជន់ជាប់ចោទឈ្មោះ ស្រ្តាយឈឺ (Streicher) គ្រុប វ៉ុន បូលេន (Krupp von Bohlen) និងជនជាប់ចោទឈ្មោះ ហេស (Hess) ប៉ុន្តែ ការវិភាគនៅសាលាជំនុំជម្រះក្តីយោធាអន្តរជាតិមិនបានផ្តល់នូវលក្ខខណ្ឌច្បាស់លាស់សំរាប់វាយតម្លៃលើសម្បទារបស់ជនជាប់ចោទទេ ប៉ុន្តែបានដាក់សំណួរនូវសំនួរពិសេសមួយចំនួនទៅវេជ្ជបណ្ឌិត ទាក់ទងនឹងជនជាប់ចោទម្នាក់ៗ (ឧទាហរណ៍ តើគាត់ប្រក្រតី ឬមានសតិមិនប្រក្រតី) ។

សម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុងសវនាការ នៅកំរិតអន្តរជាតិ នៅតែមិនទាន់បានកំណត់ដដែលរហូតដល់ឆ្នាំ២០០៣ នៅក្នុងសំណុំរឿងចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ ស្រ្តូហ្គា (Strugar) នៅតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងក្រោយពីនោះបន្តិច នៅក្នុងសំណុំរឿងចោទប្រកាន់ទៅលើជនជាប់ចោទ ចូសេហ្វ ណាហាក (Josep Nahak) នៅតុលាការពិសេសសំរាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត ។ ខុសពីសាលាជំនុំជម្រះក្តីយោធាអន្តរជាតិខាងលើ សំណុំរឿងទាំងពីរនេះបានផ្តល់នូវស្តង់ដាច្បាស់លាស់ ដើម្បីណែនាំតុលាការអន្តរជាតិក្នុងការកំណត់សម្បទារបស់ជនជាប់ចោទ ។ យោងតាមសំណុំរឿងរបស់ ស្រ្តូហ្គា និង ណាហាក់ ចំណុចគន្លឹះនៅក្នុងការកំណត់អំពីលក្ខណៈសម្បទារបស់ជនជាប់ចោទ គឺថាតើជនជាប់ចោទអាច“អនុវត្តដោយប្រសិទ្ធិភាពនូវសិទ្ធិរបស់ខ្លួននៅក្នុងដំណើរការសវនាការកាត់ទោសគាត់”ឬទេ ។

សាលាឧទ្ធរណ៍របស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសអតីតយូហ្គោស្លាវីបានពន្យល់នៅក្នុង

សំណុំរឿងស្រូហ្គាថា ដើម្បីឲ្យមានប្រសិទ្ធិភាពក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន ជនជាប់ចោទត្រូវតែអាច “យ៉ាងមានអត្ថន័យ” ៖

១. មានសមត្ថភាពគ្រប់គ្រាន់ក្នុងការឆ្លើយបដិសេធន៍ ឬទទួលកំហុស

២. មានសមត្ថភាពយល់ដឹងពីបទចោទប្រកាន់មកលើខ្លួន

៣. មានសមត្ថភាពយល់ដឹងពីដំណើរការនីតិវិធីរបស់តុលាការ

៤. មានសមត្ថភាពយល់ដឹងអំពីភស្តុតាង

៥. មានសមត្ថភាពណែនាំមេធាវីរបស់ខ្លួន

៦. មានសមត្ថភាពយល់ដឹងពីលទ្ធផលនៃការជំនុំជម្រះ (ឧទាហរណ៍ មានសាលក្រម និង អាចត្រូវដាក់ពន្ធនាគារជាដើម)

៧. មានសមត្ថភាពផ្តល់ចម្លើយ ឬសក្ខីកម្ម

ដូច្នេះ ការកំណត់សម្បទារបស់ជនជាប់ចោទតម្រូវឲ្យមានការសម្រេចតាមច្បាប់ ដោយមានការវាយតម្លៃវិជ្ជសាស្ត្រ ។ ប្រសិនបើវាគួរឲ្យជឿ (ហៅថា“គុណភាពនៃភាពគួរឲ្យជឿជាក់”) ដែលថាជនជាប់ចោទបាត់បង់នូវសមត្ថភាពគ្រប់គ្រាន់នោះ តុលាការនឹងសម្រេចថា ជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងសវនាការ ហើយសំណុំរឿងមិនអាចដំណើរការទៅមុខទៀតបានទេ រហូតដល់ពេលមួយដែលជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ឡើងវិញ ។

## ៣. សុខភាពផ្លូវចិត្តគឺសំខាន់ដូចសុខភាពផ្លូវកាយដែលជាគន្លឹះក្នុងការពិចារណាអំពីសម្បទារបស់ជនជាប់ចោទ

លក្ខខណ្ឌដែលជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងដំណើរការសវនាការ គឺដាក់កំហិតឲ្យបញ្ចូលនូវកំរិតទាបបំផុតនៃស្តង់ដារអន្តរជាតិសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌ ។ ប្រសិនបើជនជាប់ចោទម្នាក់ត្រូវចាត់ទុកថាមិនមានសម្បទាគ្រប់គ្រាន់ ជនជាប់ចោទរូបនោះត្រូវចាត់ទុកថាអសមត្ថភាពតាមផ្លូវច្បាប់ក្នុងការការពារខ្លួន ហើយការកាត់សេចក្តីជនជាប់ចោទដែលមិនមានសម្បទាគ្រប់គ្រាន់ គឺវាដូចទៅនឹងការកាត់សេចក្តីកំបាំងមុខ (ដោយមិនមានវត្តមានរបស់ជនជាប់ចោទ) ។ សវនាការកំបាំងមុខត្រូវបានហាមឃាត់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយវិធាន៨១(១) នៃវិធានផ្ទៃក្នុង និងមាត្រា៣៥ថ្មីនៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានបញ្ចូលនូវសិទ្ធិទទួលបាននូវការជំនុំជម្រះ

ដោយត្រឹមត្រូវ និងយុត្តិធម៌ ដែលមានចែងនៅក្នុងកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ មិនតែប៉ុណ្ណោះ ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់តាមច្បាប់ក្នុងការចូលរួមដំណើរការសវនាការនោះ ការរកឃើញនេះមានសារៈសំខាន់ពាក់ពន្ធ័ទៅនឹងសិទ្ធិទទួលបានការកាត់ក្តីដោយត្រឹមត្រូវ និងយុត្តិធម៌ដទៃទៀត ដែលមានចែងនៅក្នុងមាត្រា៣៥ថ្មី ដូចជា សិទ្ធិរបស់ជនជាប់ចោទក្នុងការ "ទំនាក់ទំនងជាមួយមេធាវីការពារក្តីដែលជ្រើសរើសដោយខ្លួនឯងផ្ទាល់" "ជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយខ្លួនឯង" និង "ពិនិត្យភស្តុតាងដែលប្រឆាំងនឹងខ្លួន" ។

ដូចដែលបានរៀបរាប់ខាងលើ នៅក្នុងកំរិតអន្តរជាតិ គន្លឹះក្នុងការកំណត់សម្បទារបស់ជនជាប់ចោទ គឺថាតើជនជាប់ចោទម្នាក់មានសម្បទាផ្លូវចិត្តគ្រប់គ្រាន់ ជាជាងសម្បទាផ្លូវកាយគ្រប់គ្រាន់ ក្នុងការចូលរួមក្នុងដំណើការសវនាការ ។ ការសម្រួលផ្សេងៗអាចត្រូវបានរៀបចំសម្រាប់ជនជាប់ចោទ ដែលមានបញ្ហាសម្បទាផ្លូវកាយធ្ងន់ធ្ងរ ដូច្នេះសម្បទាផ្លូវកាយតែឯកឯងគឺកំរនឹងឲ្យតុលាការសន្និដ្ឋានថា ជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការចូលរួមក្នុងដំណើរការសវនាការណាស់ ។ ជាក់ស្តែង ជនជាប់ចោទជាច្រើនដែលមានបញ្ហាសម្បទាផ្លូវកាយធ្ងន់ធ្ងរ ត្រូវបានកាត់ទោសជាធម្មតា ចំពោះបទឧក្រិដ្ឋអន្តរជាតិនៅសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី និងតុលាការអន្តរជាតិផ្សេងទៀត ហើយប្រទេសអាល្លឺម៉ង់ បានកាត់ទោសពួកណាហ្ស៊ីចាស់ជរាជាច្រើន នៅក្នុងតុលាការព្រហ្មទណ្ឌក្នុងស្រុករបស់ខ្លួន ។ នៅពេលថ្មីៗនេះ រ៉ាត់កូ ម្ល៉ាឌិក (Ratko Mladic) ត្រូវបានរកឃើញថាមានសម្បទាគ្រប់គ្រាន់សម្រាប់ការបញ្ជូនទៅកាត់ទោសនៅទីក្រុងឡាអេ ដោយសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី ទោះបីជាសុខភាពផ្លូវកាយទ្រុឌទ្រោម នៅពេលចាប់ខ្លួនបន្ទាប់ពីមានជម្ងឺទំនងជាដាច់សរសៃឈាមខួរក្បាល ។ មានជនជាប់ចោទដែលបានរកឃើញថាមិនមានកាយសម្បទាផ្លូវកាយគ្រប់គ្រាន់ទាំងស្រុងក្នុងការចូលរួមសវនាការ គឺជនជាប់ចោទទាំងឡាយណាដែលមានជម្ងឺធ្ងន់ធ្ងរដែលអាចរស់បានតែក្នុងរយៈពេលប៉ុន្មានខែទៀតប៉ុណ្ណោះ ។

ខណៈពេលដែល តុលាការមានដំណោះស្រាយសម្រាប់ជនជាប់ចោទដែលមានសម្បទាផ្លូវកាយធ្ងន់ធ្ងរ តុលាការមានការលំបាក ក្នុងការវាយតម្លៃភាពគ្រប់គ្រាន់នៃសម្បទាជនជាប់ចោទដែលមានការចុះខ្សោយផ្នែកស្មារតី ។ តុលាការមានការលំបាកក្នុងការពិនិត្យមើលការវាយតម្លៃផ្នែកសុខភាពផ្លូវចិត្ត ដើម្បីសម្រេចអំពីស្តង់ដាអប្បរមានៃសមត្ថភាពផ្លូវចិត្តដើម្បីឲ្យជនជាប់ចោទអាច "អនុវត្តប្រកបដោយប្រសិទ្ធិភាព" នូវសិទ្ធិរបស់ខ្លួន និងលំបាកក្នុងការចាត់វិធានការចំពោះជនជាប់ចោទ ដែលត្រូវបានរកឃើញថាមិនមានសម្បទា

ផ្លូវចិត្តគ្រប់គ្រាន់ និងថាសម្បទាផ្លូវចិត្តមិនគ្រប់គ្រាន់នេះមិនដឹងជារយៈពេលណាដែលជនជាប់ចោទអាចជាសះស្បើយឡើងវិញទេ។ បញ្ហាប្រឈមមុខទាំងនេះ ត្រូវបានបង្ហាញនៅសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសអតីតយូហ្គោស្លាវី ក្នុងសំណុំរឿង ស្រូហ្កា និងសំណុំរឿង វ្ល៉ាឌីមា កូវ៉ាសេវិក (Vladimir Kovacevic)។ នៅក្នុងសំណុំរឿងស្រូហ្កា អង្គជំនុំជម្រះសាលដំបូងបានសម្រេចនៅចុងក្រោយថា ជនជាប់ចោទដែលរងគ្រោះពីបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តផ្សេងៗ គឺមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងដំណើរការសវនាការ ប៉ុន្តែតម្រូវឲ្យមានការពិនិត្យនិងការវាយតម្លៃយ៉ាងជិតដល់ដោយអ្នកជំនាញ នៅមុនពេលឈានដល់ការធ្វើការសន្និដ្ឋានអំពីលក្ខណៈសម្បទារបស់ជនជាប់ចោទ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងនៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសអតីតយូហ្គោស្លាវី បានសន្និដ្ឋានថា ជនជាប់ចោទ កូវ៉ាសេវិក គឺមិនមានសម្បទាក្នុងការចូលរួមនៅក្នុងដំណើរការសវនាការទេ ដោយបញ្ហាផ្លូវចិត្តមិនច្បាស់លាស់ (ក្រោយមកត្រូវបានគេហៅថា "រោគឆ្កួតចិត្ត")។ ជាពិសេស អង្គជំនុំជម្រះបានរកឃើញថា កូវ៉ាសេវិក មិនមានលទ្ធភាពការពារខ្លួននៅក្នុងសវនាការ មិនយល់ពីបទចោទប្រកាន់មកលើរូបគាត់ មិនយល់ពីដំណើរការនីតិវិធី មិនយល់ពីប្រសិទ្ធិភាពនៃភស្តុតាង មិនអាចណែនាំមេធាវីរបស់ខ្លួន មិនយល់ពីលទ្ធផលនៃដំណើរការសវនាការ ឬមិនអាចផ្តល់សក្ខីកម្ម។ ក្នុងសំណុំរឿងដទៃទៀតពាក់ព័ន្ធទៅនឹងជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ដែលត្រូវបានដោះលែងជាបណ្តោះអាសន្ន ជនជាប់ចោទរូបនេះបានស្លាប់នៅក្រោយពេលដោះលែងបានបន្តិច។ ចំណែកនៅក្នុងសណុំរឿងកូវ៉ាសេវិកវិញ គាត់ត្រូវបានរកឃើញថាមានសម្បទាមិនគ្រប់គ្រាន់មិនដឹងពេលណាជាសះស្បើយ តែមិនមែនជម្ងឺដែលជិតស្លាប់នោះទេ។

ចំណុចសំខាន់នៃសមត្ថភាពផ្លូវចិត្តអប្បរមា ក្នុងការវាយតម្លៃទៅលើសម្បទាតាមផ្លូវច្បាប់របស់ជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជា គឺពាក់ព័ន្ធទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ។ ភាពវង្វេងវង្វាន់របស់ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានលេចឮច្រើនឆ្នាំមកហើយ ប៉ុន្តែ ក្នុងឆ្នាំថ្មីៗនេះ អាកប្បកិរិយារបស់គាត់ មើលទៅហាក់ដូចជាកាន់តែខុសប្រក្រតីទៅៗ។ ជាងនេះទៅទៀត អាកប្បកិរិយារបស់ជនជាប់ចោទ អៀង ធីរិទ្ធិ ក្នុងកំឡុងពេលសវនាការនៅអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជាថ្មីៗនេះ មិននឹងធឹង ដូចជា វង្វេងវង្វាន់ ច្របូកច្របល់ និង ស្ងប់ស្ងាត់ដោយមិនយកចិត្តទុកដាក់។ អាកប្បកិរិយានេះគួបផ្សំនឹងការអះអាងរបស់ ក្រុមមេធាវីការពារក្តីរបស់គាត់ដូចដែលបានបង្ហាញខាងលើ បានធ្វើឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំងទៅលើសុខភាពផ្លូវចិត្តរបស់ជនជាប់ចោទ អៀង ធីរិទ្ធ។ ការព្រួយបារម្ភនេះ

កាន់តែកើនឡើងថែមទៀត ដោយសារតែប្រវត្តិគ្រួសាររបស់ជនជាប់ចោទ អៀង ធីរិទ្ធ។ បងស្រីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ឈ្មោះ ខៀវ ប៉ុណ្ណារី ត្រូវបានជឿជាក់យ៉ាងពិតប្រាកដថា មានជម្ងឺវិកលចរិត។ ខៀវ ប៉ុណ្ណារី ជាប្រពន្ធទីមួយរបស់ ប៉ុល ពត ហើយជាបញ្ញវន្តជាន់ខ្ពស់មួយរូបនៅកម្ពុជា នៅមុនសម័យខ្មែរក្រហម។ គាត់សិក្សានៅប្រទេសបារាំងជាមួយនឹងប្អូនស្រីរបស់គាត់ ហើយត្រូវបានចាត់ទុកជាអ្នកស្រាវជ្រាវ និងជាគ្រូបង្រៀននាំមុខម្នាក់នៅប្រទេសកម្ពុជា។ប៉ុន្តែនៅមុនឆ្នាំ១៩៧៥ សុខភាពផ្លូវចិត្តរបស់ ខៀវ ប៉ុណ្ណារី ចាប់ផ្តើមធ្លាក់ចុះ ហើយគាត់បានដកខ្លួនចេញពីការបង្ហាញខ្លួនជាសាធារណៈ។ ចុងក្រោយ ខៀវ ប៉ុណ្ណារី ត្រូវបានថែទាំដោយ អៀង ធីរិទ្ធ និង អៀង សារី រហូតដល់ពេលដែលគាត់ទទួលមរណភាព ហើយ ខៀវ ប៉ុណ្ណារី ប្រហែលជាអាចមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងររហូតដល់ទៅសាមសិបឆ្នាំ ពេលដែលគាត់បាត់បង់ជីវិតនៅឆ្នាំ ២០០៣។

## ៤. ផលប៉ះពាល់នៅពេលដែលជនជាប់ចោទត្រូវរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការសវនាការ

តាមទ្រឹស្តី លទ្ធផលនៃការរកឃើញថាជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការសវនាការ គឺសាមញ្ញបំផុត។ នៅក្នុងសាលាជម្រះក្តីអន្តរជាតិ និង តុលាការព្រហ្មទណ្ឌជាតិភាគច្រើន ជនជាប់ចោទដែលមិនមានសម្បទាគ្រប់គ្រាន់ ជាធម្មតា ត្រូវបញ្ជូនទៅកាន់មន្ទីរព្យាបាលសមរម្យមួយដែលជាកន្លែងដែលជនជាប់អាចទទួលការព្យាបាលផ្លូវចិត្ត រហូតដល់ពេលដែលមានសម្បទាគ្រប់គ្រាន់ឡើងវិញ។ នៅក្នុងចន្លោះពេលនេះ ដំណើរការសវនាការត្រូវផ្អាក ដោយរំពឹងថា ប្រសិនបើជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ឡើងវិញនោះ ដំណើរការត្រូវចាប់បន្តជាបន្ទាន់ចាប់ពីដំណាក់កាលផ្អាកនោះ។ ឧទាហរណ៍ នៅក្នុងករណីរបស់ កូវ៉ាសេវិក នៅសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីដែលរកឃើញថា ជនជាប់ចោទមិនមានសម្បទាក្នុងការចូលរួមដំណើរការសវនាការដោយមិនដឹងថាពេលណាដែលអាចចូលរួមបានវិញ "ដោយមានលក្ខណ្ឌថា ជនជាប់ចោទនឹងត្រូវយកមកជំនុំជម្រះបន្ត នៅពេលដែលស្ថានភាពសុខភាពផ្លូវចិត្តរបស់គាត់មានការប្រែប្រួល។"

ជាក់ស្តែង វាកម្រណាស់ដែលជនជាប់ចោទមានជម្ងឺផ្លូវចិត្តក្នុងរយៈពេលខ្លីដែលអាចព្យាបាលបាន។ ភាគច្រើន ជនជាប់ចោទដែលរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់តាមផ្លូវច្បាប់ ច្រើនតែមានជំងឺដែលធ្ងន់ឡើងជាលំដាប់ មិនអាចព្យាបាលបាន ក្រៅពីការស្លាប់។ ឧទាហរណ៍ នៅសាលាជំនុំជម្រះក្តីយោធាអន្តរជាតិ

ជនជាប់ចោទ គ្រុប វ៉ុន បូលេន ដែលជាខុស្សាហកក្នុងសង្គ្រាមអាល្លឺម៉ង់ម្នាក់ ត្រូវជាប់ចោទពីបទប្រើប្រាស់មនុស្សនៅក្នុងជំរំប្រមូលផ្តុំជាទាសករនៅក្នុងរោងចក្ររបស់គាត់នៅក្នុងសម័យសង្គ្រាមលោកលើកទី២ ត្រូវបានប្រកាសថា មិនមានសម្បទាគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះក្តី ភ្លាមៗបន្ទាប់ពីការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងឆ្នាំ១៩៤៥ ។ វ៉ុន បូលេន មានជម្ងឺដាច់សរសៃឈាមខួរក្បាលយ៉ាងធ្ងន់ធ្ងរនៅក្នុងឆ្នាំ១៩៤១ ដែលធ្វើឲ្យគាត់ពិការខ្វះៗ និងមិនអាចផ្លាស់ទីបាន ។ បន្ទាប់ពីចោទប្រកាន់ វ៉ុន បូលេន ប៉ុន្តែនៅមុនពេលចាប់ខ្លួនគាត់ សាលាជំនុំជម្រះក្តីយោធាអន្តរជាតិ បានតែងតាំងពេទ្យយោធាអាមេរិកមួយរូបដែលយល់ឃើញថា វ៉ុន បូលេន «មិនមានសម្បទាផ្លូវចិត្តគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះក្តីទេ» និង បាន «បាត់បង់សម្ថភាពចងចាំ ឲ្យហេតុផល ឬយល់អំពីពាក្យសំដីដែលនិយាយទៅកាន់គាត់» ។ វេជ្ជបណ្ឌិតរូបនោះ យល់ឃើញទៀតថា នឹងអាចប៉ះពាល់ដល់អាយុជីវិតរបស់ វ៉ុន បូលេន ប្រសិនបើគាត់ត្រូវគេដឹកទៅជំនុំជម្រះនៅតុលាការ ។ វ៉ុន បូលេន មិនត្រូវបានចាប់ខ្លួនទេ ប៉ុន្តែ ស្ថិតនៅក្រោមដីការចោទប្រកាន់រហូតដល់ការស្លាប់របស់គាត់នៅឆ្នាំ១៩៥០ ។

ជនជាប់ចោទ រូដុហ្វ ហេស ពួកណាហ្ស៊ីតំណែងធំជុំម្នាក់ ក៏បានលើកឡើងនូវបញ្ហាសមត្ថភាពផ្លូវចិត្តដែរ នៅឯសាលាជំនុំជម្រះក្តីយោធាអន្តរជាតិ នៅនូរឹមបឺក ។ មេធាវីរបស់ ហេស បានស្នើសុំឲ្យមានការវាយតម្លៃសុខភាពរបស់ជនជាប់ចោទ ដោយអះអាងថា ជនជាប់ចោទ«បាត់បង់ការចងចាំទាំងស្រុង» ។ ការវាយតម្លៃរបស់គ្រូពេទ្យជំនាញបានដាក់របាយការណ៍បីដែលបានសន្និដ្ឋានថា ហេស មានស្មារតីធម្មតា ប៉ុន្តែ គាត់បាត់បង់ការចងចាំដោយសារ«ការរំជួលចិត្តខ្លាំង» ។ នៅក្នុងហេតុការណ៍គួរឲ្យភ្ញាក់ផ្អើលមួយ ហេស បានប្រកាសថាខ្លួនគាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ នៅក្នុងសវនការពិនិត្យមើលសម្បទារបស់គាត់ ហើយអះអាងថា គាត់ធ្វើពុតជាបាត់ការចងចាំជាយុទ្ធសាស្ត្ររបស់គាត់ ។ ប៉ុន្តែ ការមន្ទិលសង្ស័យនៅតែមានជាបន្ត សូម្បីតែចំពោះក្រុមព្រះរាជអាជ្ញានៅក្នុងសំណុំរឿងរបស់ ហេស អំពីសមត្ថភាពរបស់គាត់ក្នុងការចូលរួមនៅក្នុងសវនាការ រហូតដល់ការសំលាប់ខ្លួនរបស់គាត់ជានៅក្នុងពន្ធនាគារកាលពីឆ្នាំ១៩៨៧ ។

ករណីរបស់ កូវ៉ាសេវិក នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី ក៏បានបង្ហាញពីការលំបាកក្នុងការកំណត់ពីសមត្ថភាពផ្នែកស្មារតីដើម្បីចូលរួមនៅក្នុងសវនាការ និង ការស្វែងរកដំណោះស្រាយសមរម្យមួយសម្រាប់ជនជាប់ចោទដែលមិនមានសម្បទាគ្រប់គ្រាន់ ។ កូវ៉ាសេវិក ត្រូវបានចោទប្រកាន់នៅខែមីនា ឆ្នាំ២០០១ ហើយត្រូវបានរកឃើញជាលើកដំបូងថាមិនមានសម្បទាគ្រប់

គ្រាន់ក្នុងការចូលរួមក្នុងសវនាការនៅខែមិថុនា ឆ្នាំ២០០៤ នៅពេលនោះគាត់ត្រូវបានដោះលែងបណ្ដោះអាសន្នរយៈពេលប្រាំមួយខែ ឲ្យធ្វើដំណើរទៅកាន់ស៊ែប៊ី និងម៉ុងតេនេក្រូដើម្បីទទួលការព្យាបាលពីគ្រូពេទ្យ ។ ក្រោយពីការពន្យាពេលបន្ថែមនូវការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន និង បន្ទាប់ពីមានការពិនិត្យវេជ្ជសាស្ត្រ និងរបាយការណ៍ជាច្រើនរបស់អ្នកជំនាញប៉ុណ្ណោះ ទើបតុលាការប្រកាសថា កូវ៉ាសេវិក មិនមានសម្បទាគ្រប់គ្រាន់ដែលមិនដឹងថាពេលណាទើបជាសះស្បើយឡើងវិញ នៅខែមេសា ឆ្នាំ២០០៦ ។ នៅខែវិច្ឆិកា ឆ្នាំ២០០៦ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបានទទួលយកសំណើររបស់ព្រះរាជអាជ្ញា ឲ្យបញ្ជូន កូវ៉ាសេវិក ទៅស៊ែប៊ី ជាកន្លែងដែលគាត់អាចត្រូវកាត់ទោសដោយតុលាការក្នុងស្រុក ប្រសិនបើគាត់អាចមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការឡើវិញ ។ នៅក្នុងខណៈពេលនោះ កូវ៉ាសេវិក ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យយោធាយ៉ាងមានសុវត្ថិភាព ដើម្បីទទួលការព្យាបាលជម្ងឺនៅទីនោះតែម្ដង ។ ព្រះរាជអាជ្ញាស៊ែប៊ី បានចោទប្រកាន់ កូវ៉ាសេវិក ក្នុងតុលារការក្រុងបែលក្រាតក្នុងខែកក្កដា ២០០៧ ។ ក៏ប៉ុន្តែ តុលាការបានរកឃើញថា កូវ៉ាសេវិក នៅបន្តមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការនៅខែវិច្ឆិកា ឆ្នាំ២០០៧ ហើយជនជាប់ចោទបន្តស្ថិតនៅក្នុងការគ្រប់គ្រងរបស់មន្ទីរពេទ្យយោធានោះ ។ ចាប់តាំងពីពេលនោះមក មិនមានការប្រកាសណាមួយសំរាប់គម្រោងបន្ថែមទៀតសម្រាប់ការចោទប្រកាន់ កូវ៉ាសេវិក ហើយវាហាក់ដូចជាគាត់នឹងបន្តនៅក្នុងមន្ទីរពេទ្យជារៀងរហូតប្រហែលជាអាចរហូតដល់ការស្លាប់របស់គាត់ទៀតផង ។

បទពិសោធន៍ច្បាប់ក្នុងសំណុំរឿង វ៉្លាឌីមា កូវ៉ាសេវិក បង្ហាញឲ្យឃើញពីការប្រឈមរបស់តុលាការកាត់ទោសជនជាប់ចោទដែលមានបញ្ហាសុខភាពទ្រុឌទ្រោមយូរអង្វែង និងដែលត្រូវចោទប្រកាន់ពីបទល្មើសយ៉ាងធ្ងន់ធ្ងរ ។ ការប្រឈមទាំងនេះកាន់តែលំបាកថែមទៀតសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយសារតែកម្ពុជាខ្វះខាតមន្ទីរពេទ្យទូទៅ ហើយជាពិសេស ខ្វះខាតមន្ទីរពេទ្យសុខភាពផ្លូវចិត្ត ។ ដោយឡែក ការខ្វះខាតនេះគឺជាកេរ្តិ៍ដំណែលរបស់របបខ្មែរក្រហមដែលបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និងបានកាប់សម្លាប់អ្នកជំនាញផ្នែកសុខភាព ។

### ៥. លទ្ធផលនៅពេលជនជាប់ចោទត្រូវរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការរបស់អង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ការដោះលែងដោយគ្មានលក្ខខណ្ឌគឺជាការកម្រមបំផុត នៅពេលដែលជនជាប់ចោទត្រូវរកឃើញថា

មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការ ។ វ៉ុន បូលេន មិនដែលធ្លាប់ត្រូវឃុំឃាំងឡើយ ដោយសារគាត់មានជំងឺធ្ងន់ធ្ងរ និង មានសភាពវង្វេងវង្វាន់រួចទៅហើយនៅពេលត្រូវចោទប្រកាន់ដោយសាលាជំនុំជម្រះក្តីយោធាអន្តរជាតិ ហើយគាត់មិនមានសភាពធូរស្បើយឡើងវិញទេនៅមុនពេលគាត់ស្លាប់ក្នុងឆ្នាំ១៩៥០ ។ នៅឯសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី ជនជាប់ចោទ ជត ឌូគិច ត្រូវបានចោទប្រកាន់ ហើយបន្ទាប់មកត្រូវបានដោះលែងដោយតុលាការនៅចុងខែមេសា ឆ្នាំ១៩៩៦ ដោយសារតែរូបគាត់មានបញ្ហាជំងឺមហារីក ។ អង្គជំនុំជម្រះអនុញ្ញាតឲ្យ ឌូគិច ត្រឡប់ទៅប្រទេសស៊ែប៊ី វិញ ជាមួយនឹងគ្រួសាររបស់គាត់ ហើយនៅរក្សាសិទ្ធិចោទប្រកាន់គាត់ដដែល នៅពេលណាដែលគាត់សះស្បើយឡើងវិញ ។

ឌូគិច បានស្លាប់មុនរយៈពេលបីខែ ក្រោយពីគាត់ត្រូវដោះលែងនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៦ ។ ករណីរបស់ វ៉ុន បូលេន និង ឌូគិច នេះ គឺជាករណីពិសេស ដោយសមត្ថភាពរបស់ពួកគេបានបាត់បង់ទាំងស្រុង ដោយសារតែជនជាប់ចោទត្រូវរកឃើញថានឹងបាត់បង់ជីវិតក្នុងរយៈពេលកំណត់មួយខាងមុខ ។

នៅពេលជនជាប់ចោទណាមួយត្រូវរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ ប៉ុន្តែ ស្ថានភាពរបស់ជនជាប់ចោទគឺមិនស្លាប់នៅក្នុងពេលណាមួយខាងមុខទេ យ៉ាងហោចណាស់ក្នុងរយៈពេលខ្លីមួយខាងមុខទេ តុលាការជាធម្មតាបានផ្ទេរជនជាប់ចោទទៅកាន់កន្លែងព្យាបាល រង់ចាំរហូតដល់ជនជាប់ចោទមានសម្បទាគ្រប់គ្រាន់តាមផ្លូវច្បាប់ឡើងវិញ ។ ដូច្នេះ តាមទ្រឹស្តី ប្រសិនបើជនជាប់ចោទណាមួយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការទេ ជនជាប់ចោទនោះត្រូវបញ្ជូនទៅកន្លែងព្យាបាលសមរម្យមួយ រហូតដល់ជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ឡើងវិញ ។ ការផ្ទេរទៅកន្លែងព្យាបាលនេះគឺអាចមិនមានពេលកំណត់ទេ ដូចនៅក្នុងករណីរបស់ វ្លាឌីមា កូវ៉ាសេវិក ។

ជាក់ស្តែង វាប្រហែលជាមិនអាចទៅរួចទេ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលប្រសិនបើជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ ហើយអាចត្រឡប់មកទទួលការជំនុំជម្រះជាបន្តនៅក្នុងករណីដែលជនជាប់ចោទរូបនោះសះស្បើយឡើងវិញ ។ មានមូលហេតុ បីយ៉ាង ៖

ទី១. មន្ទីរព្យាបាលសមរម្យមួយប្រហែលជាមិនមានទេនៅក្នុងប្រទេសកម្ពុជា ជាពិសេសចំពោះជនជាប់ចោទដែលត្រូវបានរកឃើញថាមានបញ្ហាផ្លូវចិត្ត ។

ទី២. ដោយយោងតាមវ័យចាស់ជរារបស់ជនជាប់ចោទនៅក្នុងសំណុំរឿង០០២ សម្បទារបស់ជនជាប់ចោទមិនទំនងជានឹងស្តារឡើងវិញទេ បើទោះជាមានការព្យាបាលលំដាប់សកលលោកក៏ដោយ ។ វាទំនងច្រើនជាងដែលថា ប្រសិនបើជនជាប់ចោទណាម្នាក់ត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ចូលរួមក្នុងដំណើរការសវនាការទេ ជនជាប់ចោទនោះទំនងជាមិនអាចមានសម្បទាគ្រប់គ្រាន់តាមផ្លូវច្បាប់រហូតដល់ការស្លាប់របស់ជនជាប់ចោទនោះតែម្តង ។

ទី៣. ចុងបញ្ចប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាស្ថាប័នតុលាការបណ្តោះអាសន្នមួយដែលការងារមានកំណត់ ដូច្នេះបើទោះបីជាជនជាប់ចោទនៅក្នុងសំណុំរឿង០០២មានសម្បទាគ្រប់គ្រាន់ឡើងវិញក៏ដោយ ក៏តុលាការប្រហែលជាមិនអាចបន្តមានវត្តមានដើម្បីធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទដែរ ។

ជាការពិត ប្រសិនបើជនជាប់ចោទត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លទ្ធផលភាគច្រើនដែលអាចកើតឡើងនោះ គឺជនជាប់ចោទត្រូវបានដោះលែងបណ្តោះអាសន្ន ដោយមានការដាក់កំហិតលើសេរីភាពរបស់ជនជាប់ចោទនោះ ។ ការដោះលែងបណ្តោះអាសន្ននេះ ទំនងជានឹងឲ្យជនជាប់ចោទស្ថិតក្រោមការឃាត់ខ្លួននៅក្នុងមន្ទីរពេទ្យ ។ ប៉ុន្តែ នៅពេលដែលមានការដោះលែងនេះមែន ឱកាសដែលជនជាប់ចោទអាចត្រលប់មកទទួលទទួលការជំនុំជម្រះនៅសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិញនោះគឺមានតិចតួចណាស់ ។ ផ្ទុយទៅវិញបើយោងតាមអាយុចាស់ជរារបស់ពួកគេ ភាគច្រើនគឺសុខភាពរបស់ពួកគេគឺទំនងជាកាន់តែថមថយជាជាងប្រសើឡើង និងប្រហែលជាអាចស្លាប់ដោយមិនទាន់បានទទួលការជម្រះចប់ផង ។ ដំណើរការនេះអាចត្រូវពន្យាពេលជាពិសេសនៅក្នុងករណីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលមានបញ្ហាសុខភាពផ្លូវចិត្តយ៉ាប់យឺន នេះបើតាមការលើកឡើងដោយមេធាវីការពារក្តី ។ វាជាការមួយកម្រណាស់ដែលសមត្ថភាពផ្លូវចិត្តរបស់បុគ្គលណាម្នាក់ ដែលមានសមត្ថភាពផ្លូវចិត្តយ៉ាប់យឺន អាចជាសះស្បើយឡើងវិញនោះ ។ ជាទូទៅបុគ្គលម្នាក់ដែលមានបញ្ហាផ្លូវចិត្ត ដូចជាករណីបងស្រីរបស់ អៀង ធីរិទ្ធ ឈ្មោះ ខៀវ ប៉ុណ្ណារី អាចរស់រានមានជីវិតរយៈពេលវែង ប៉ុន្តែ មិនមានការជាសះស្បើយឡើវិញនូវសមត្ថភាពខាងផ្លូវចិត្តទេ ។